នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Sep-2011, 14:12
CMS/CFO: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស ឬ អង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ស្នើសុំសេចក្តីណែនាំពាក់ព័ន្ធនឹង ចេតនារបស់ជនជាប់ចោទ ទាក់ទងនឹងការផ្តល់សក្ខីកម្ម

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម

លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក ស សូវាន
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញាសូមគោរពបញ្ជាក់ពីសំណើរបស់ខ្លួនឡើងវិញ ដែលបានដាក់កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ស្នើសុំឱ្យចេញសេចក្តីណែនាំមួយដល់ជនជាប់ចោទ ឱ្យផ្តល់ព័ត៌មានជូនអង្គជំនុំជម្រះ និងភាគីដទៃទៀត ថាតើពួកគាត់នឹងផ្តល់នូវភ័ស្តុតាងផ្ទាល់មាត់នៅពេលសវនាការដែរ ឬទេ។ សហព្រះរាជអាជ្ញាស្នើថាសេចក្តីណែនាំនេះត្រូវចេញក្នុងលក្ខណៈជាការប្រញាប់ ដោយសារតែភាពជឿនលឿននៃការត្រៀមរៀបចំសវនាការ និងនៅសល់រយៈពេលតិចតួចប៉ុណ្ណោះ មុនពេលមានការចាប់ផ្តើមដំណើរការនីតិវិធីលើអង្គសេចក្តី។

## II. ប្រវត្តិនីតិវិធីបច្ចុប្បន្ន

២. បញ្ហានេះត្រូវបានការិយាល័យសហព្រះរាជអាជ្ញាលើកឡើងដំបូង នៅក្នុងកិច្ចប្រជុំត្រៀមរៀបចំសម្រាប់សវនាការ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១។ សហព្រះរាជអាជ្ញារងអន្តរជាតិបានស្នើថា គេត្រូវបង្គាប់ឱ្យ ជនជាប់ចោទជូនដំណឹងដល់អង្គជំនុំជម្រះ និងភាគីដទៃទៀត ថាតើពួកគាត់មានបំណងនឹងផ្តល់នូវសក្ខីកម្មដែរ ឬទេ។ គាត់បានបញ្ជាក់ថា ការណ៍នេះគឺចាំបាច់ដើម្បីជួយដល់ភាគីនានា និងទាំងអង្គជំនុំជម្រះ ក្នុងការត្រៀមរៀបចំសម្រាប់សវនាការ ដោយសារតែមានផលប៉ះពាល់សំខាន់ ដែលថាសេចក្តីសម្រេចចិត្តរបស់ជនជាប់ចោទ នឹងមានទៅលើដំណាក់កាលដំបូងនៃករណីរឿងក្តីនេះ[1]។

៣. នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់ជូននូវសំណើជាលាយលក្ខណ៍អក្សរមួយ ដែលស្នើសុំឱ្យអង្គជំនុំជម្រះបង្គាប់ដល់ជនជាប់ចោទឱ្យថ្លែងថាតើពួកខ្លួនមានបំណងផ្តល់នូវភ័ស្តុតាងដោយផ្ទាល់មាត់នៅពេលសវការដែរ ឬទេ។ សហព្រះរាជអាជ្ញាបានកត់សម្គាល់ថាជាលក្ខណៈមួយនៃនីតិវិធីតាមប្រព័ន្ធច្បាប់ស៊ីវិលដែលនៅជាធរមាននៅចំពោះមុខ អវតក ដែលថាគេត្រូវឱ្យជនជាប់ចោទផ្តល់សក្ខីកម្មនៅពេលចាប់ផ្តើមធ្វើសវនាការ។ សហព្រះរាជអាជ្ញាក៏បាន

[1] **E1/2.1** ប្រតិចារឹកនៃកិច្ចប្រជុំរៀបចំសវនាការ, ថ្ងៃទី៨ មេសា ២០១១, ត្រង់ទំព័រទី ៥៤-៥៥ ។

បរិយាយផងដែរ អំពីសារសំខាន់នៃការជូនដំណឹងដល់ភាគីនានា និងទាំងអង្គជំនុំជម្រះ អំពីចេតនារបស់ជនជាប់ចោទទាក់ទិននឹងបញ្ហានេះ[2]។

## III. សំណើ

៤. ដោយហេតុថាការចាប់ផ្តើមនៃសវនាការលើអង្គសេចក្តីបានខិតចូលជិតមកដល់ហើយនោះ វាមានលក្ខណៈដាច់ខាតមួយដែលអង្គជំនុំជម្រះត្រូវបង្គាប់ដល់ជនជាប់ចោទឲ្យថ្លែងថា តើខ្លួនមានបំណងផ្តល់សក្ខីកម្មក្នុងនាមខ្លួនផ្ទាល់ឯងដែរ ឬទេ។ នៅក្នុងដីកាកំណត់កាលបរិច្ឆេទ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ អង្គជំនុំជម្រះបានកត់សម្គាល់ថាមិនមានបញ្ហាទាក់ទងទៅនឹងសម្បទារបស់ ខៀវ សំផន និង អៀង សារី ក្នុងការចូលរួមសវនាការទេ[3]។ ថ្មីៗនេះ សហព្រះរាជអាជ្ញាបានដាក់ជូននូវសេចក្តីសន្និដ្ឋានថាមិនចាំបាច់តម្រូវឲ្យមានការសួរនាំអំពីសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការបន្ថែមទៀតទេ[4]។ ដោយមានរបាយការណ៍របស់អ្នកជំនាញលើ អៀង ធីរិទ្ធ នៅចុងខែកញ្ញា ឆ្នាំ២០១១[5] នោះការពិចារណាអំពីសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ គឺត្រូវស្ថិតនៅក្នុងដំណាក់កាលដ៏ឆាប់មួយ ហើយឆាប់ៗនេះ អង្គជំនុំជម្រះទំនងជានឹងត្រូវស្ថិតនៅក្នុងគោលជំហរមួយដែលត្រូវធ្វើសេចក្តីសម្រេចនៅពេលក្រោយបន្ទាប់មកទៀត។ អង្គជំនុំជម្រះបានទទួលឯកសារ និងបញ្ជីសាក្សីដែលភាគីបានស្នើឡើង[6]។ នៅសវនាការបឋមដែលបានធ្វើឡើងនៅ ខែមិថុនា

[2] **E101** សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំសេចក្តីណែនាំទាក់ទងនឹងចេតនារបស់ជនជាប់ចោទពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្ម, ថ្ងៃទី១៧ មិថុនា ២០១១, ត្រង់កថាខណ្ឌទី ២ និង ៣ ។

[3] **E110** ដីកាកំណត់កាលបរិច្ឆេទសវនាការស្តីពីកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ, ថ្ងៃទី១១ សីហា ២០១១ ។

[4] **E115/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់មេធាវីការពារក្តីស្នើឲ្យចាត់តាំងអ្នកជំនាញបន្ថែមទៀត, ថ្ងៃទី១២ កញ្ញា ២០១១, ត្រង់កថាខណ្ឌទី ២៧ ។

[5] **E111** ដីកាចាត់តាំងអ្នកជំនាញ, ថ្ងៃទី២៣ សីហា ២០១១ ។

[6] **E109/4** ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំឯកសារដែលទាក់ទិននឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី, ថ្ងៃទី២២ កក្កដា ២០១១ ។ **E109/3** ការកត់សម្គាល់អំពីឯកសារដែលពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូង, ថ្ងៃទី២២ កក្កដា ២០១១ ។ **E109** ការបញ្ជាក់ឯកសារទាំងឡាយពាក់ព័ន្ធនឹងដំណាក់កាលដំបូងនៃការជំនុំជម្រះពីសហមេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ, ថ្ងៃទី២២ កក្កដា ២០១១ ។ **E109/2** បញ្ជីឯកសារពិនិត្យសារឡើងវិញ និងវត្ថុតាងពាក់ព័ន្ធនឹងដំណាក់កាលដំបូងទាំងបួននៃការជំនុំជម្រះ របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ថ្ងៃទី២២ កក្កដា ២០១១ ។ **E109/1** បញ្ជីឯកសារសម្រាប់ដំណាក់កាលដំបូងនៃសវនាការ, ថ្ងៃទី២២ កក្កដា ២០១១ ។ **109/6** បញ្ជីឯកសារ និងវត្ថុតាងរបស់ អៀង សារី សម្រាប់ប្រធានបទជំនុំជម្រះដំបូង, ថ្ងៃទី២២ កក្កដា ២០១១ ។ **E9/4** បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធ

ឆ្នាំ២០១១ អង្គជំនុំជម្រះបានចេញបញ្ជីឈ្មោះសាក្សីបណ្តោះអាសន្នរបស់ខ្លួន សម្រាប់ដំណាក់កាលដំបូងនៃសវនាការ ហើយនៅថ្ងៃទី៥ ខែកក្កដា ភាគីនានាបានដាក់ជូននូវសំណើបន្ថែមរបស់ពួកខ្លួនដែលពាក់ព័ន្ធទៅនឹងបញ្ជីឈ្មោះនោះ[7]។

៥. ពេលវេលាសម្រាប់ជនជាប់ចោទធ្វើការថ្លែងពីបំណងរបស់ខ្លួនទាក់ទងទៅនឹង<u>ការផ្តល់ភ័ស្តុតាង</u> គឺក្នុងពេលនេះហើយ។ ការពន្យារណ៍ពេលណាមួយក៏ដោយដែលទាក់ទងទៅនឹងបញ្ហានេះ នឹងរារាំងដល់ការត្រៀមរៀបចំផ្សេងៗរបស់អង្គជំនុំជម្រះ និងភាគីនានា រួមទាំងក្រុមមេធាវីការពារក្តីនីមួយៗផង ដោយសារតែវិសាលភាព និងចរិតលក្ខណៈនៃការចោទប្រកាន់លើអង្គហេតុនានានៅក្នុងដីកាដំណោះស្រាយ។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើថា សូមឲ្យអង្គជំនុំជម្រះចេញដីកាបង្គាប់មួយឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន៖

ក) ដោយរំលឹកដល់ជនជាប់ចោទម្នាក់ៗថាពួកគេអាចផ្តល់សក្ខីកម្មនៅពេលចាប់ផ្តើមសវនាការ, និង

---

សម្ងាត់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និង ទី៥, ថ្ងៃទី២៨ មករា ២០១១ ។ **E9/4/4** បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើងដោយមេធាវីការពារក្តី នួន ជា, ថ្ងៃទី១៥ កុម្ភៈ ២០១១ ។ **E9/4/2** បញ្ជីស្នើឈ្មោះអ្នកជំនាញរបស់លោក អៀង សារី និងសេចក្តីជូនដំណឹងរបស់លោក អៀង សារី ទាក់ទងនឹងបញ្ជីឈ្មោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់, ថ្ងៃទី១៤ កុម្ភៈ ២០១១ ។ **E9/4/5** បញ្ជីឈ្មោះអ្នកជំនាញ និងសាក្សីរបស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ, ថ្ងៃទី១៥ កុម្ភៈ ២០១១ ។ **E9/4/6** បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ, ថ្ងៃទី២១ កុម្ភៈ ២០១១ ។ **E9/4/3** បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន៨០ រួមទាំងឧបសម្ព័ន្ធសម្ងាត់១, ២ក, ២ខ, ៣ក, ៣ខ និង ៤ ។

[7] **E93/7** សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យស្តាប់អ្នកជំនាញ ២រូប និងសាក្សី ១២រូប បន្ថែម នៅក្នុងដំណាក់កាលដំបូងនៃសវនាការ និងការជូនដំណឹងអំពីចេតនាដាក់ឈុតវីដេអូខ្លីៗចំនួន៧ ទាក់ទងទៅនឹង នួន ជា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមវិធាន៨៧(៤), ថ្ងៃទី៥ កក្កដា ២០១១ ។ **E93/9** សំណើសុំបន្ថែមសាក្សី និង បន្តសវនាការបឋម, ថ្ងៃទី៥ កក្កដា ២០១១ ។ **E93/8** សំណើសុំដាក់បន្ថែមសាក្សីទៅក្នុងបញ្ជីឈ្មោះបណ្តោះអាសន្នសម្រាប់ដំណាក់កាលដំបូងៗនៃការជំនុំជម្រះ, ថ្ងៃទី៥ កក្កដា ២០១១ ។ **E93/6** សេចក្តីសង្កេតរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅលើបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញបណ្តោះអាសន្ន ដែលរៀបចំដោយអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី៥ កក្កដា ២០១១ ។

ខ) ដោយបង្គាប់ពួកគាត់ឲ្យថ្លែងនៅក្នុងរយៈពេលចំនួនប្រាំពី(០៧)ថ្ងៃ គិតពីថ្ងៃចេញដីកាបង្គាប់របស់អង្គជំនុំជម្រះ ថាតើពួកគាត់នឹងផ្តល់សក្ខីកម្ម ដែរឬ ទេ ឬមួយក៏អនុវត្តនូវសិទ្ធិរបស់ពួកគាត់ក្នុងការស្ថិតនៅស្ងៀមមិននិយាយ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |